

# ប្រាជ្ញ និង សាថេ

Huot Sarith

Ouk Ratha

letsreadasia.org



ខ្ញុំបាទឈ្មោះប្រាជ្ញរៀននៅថ្នាក់ទី៤«ក»នៃសាលាបឋមសិក្សារាំងទ។ ពុកខ្ញុំទៅធ្វើការនៅភ្នំពេញបាត់ៗ។ ម៉ែខ្ញុំទៅធ្វើការនៅផ្ទះគ្រួសារមួយ នៅចុងភូមិ។ដូច្នេះខ្ញុំច្រើននៅជាមួយយាយ។



តាំងពីចុងខែធ្នូមក ខ្ញុំត្រូវសិស្សម្នាក់
គំរាមយកលុយជារៀងរាល់ថ្ងៃ។ គេ
ឈ្មោះ សាថេ រៀនថ្នាក់ទី៦។ គេហាមខ្ញុំ
មិនឱ្យនិយាយប្រាប់គេឡើយ។ បើមិន
ដូច្នេះគេនឹងមិនឱ្យខ្ញុំបានសុខឡើយ។
ខ្ញុំមិនដឹង ត្រូវធ្វើយ៉ាងណាឡើយ។



ពីពេលនោះមក ខួរក្បាលខ្ញុំដូចជា
ស្ពឹកៗយ៉ាងម៉េចមិន ដឹងទេ! នៅផ្ទះ
លំហាត់ដែលម៉ែតែងដាក់ឱ្យធ្វើពេល
ល្ងាចៗ ក៏ខ្ញុំធ្វើមិនបានល្អដូចមុនៗ។ ឯ
នៅសាលា ខ្ញុំស្តាប់គ្រូពន្យល់មិនចូល
សោះ។ តាមធម្មតា រៀនជាមួយអ្នកគ្រូ
បីរ៉ាម៉ូ ខ្ញុំឆាប់យល់ណាស់។




អ្នកគ្រូកំពុងកែកិច្ចការប្រឡងប្រចាំខែ
មករា។ ពេលនោះគាត់ឃើញកិច្ចការខ្ញុំ
ខុសច្រើន ប្លែកពីធម្មតា។ គាត់ក៏ហៅ
ខ្ញុំមកសួរនាំ ៖ - ប្រាជ្ញ! កូនមានរឿង
អី? ម៉េចបានធ្វើខុសស្ទើរតែគ្រប់សំណួរ
អ៊ីចឹង? - អត់មានអីទេអ្នកគ្រូ! (ខ្ញុំ
ឆ្លើយតបទាំងព្រលឹងមិននៅក្នុងខ្លួន)



ពេលគាត់សួរ ខ្ញុំហាមាត់និយាយ
ការពិតមិនរួចសោះ។ នេះព្រោះតែ
ខ្ញុំខ្លាច សាថេ វាយធ្វើបាប! ទោះជា
យ៉ាងនេះក្តី អ្នកគ្រូហាក់មិនជឿខ្ញុំទេ។
ព្រោះគាត់បានលួចសួរវេទី ដែលជាមិត្ត
រួមថ្នាក់ដ៏ជិតស្និទ្ធរបស់ខ្ញុំ ។ នាងបាន
លួចសួរខ្ញុំ ពេលកំពុងរៀន ៖ - ឯងធ្វើអី
ខុសបានជាអ្នកគ្រូមកសួរខ្ញុំពីម្សិលមិញ
ពេលចេញទៅផ្ទះ?



ខ្ញុំមិនបានដឹងថា វេទី លួចតាមដានខ្ញុំ ពីពេលណាមកទេ។ ខ្ញុំភ្ញាក់ព្រើតពេល អ្នកគ្រូហៅខ្ញុំទៅសួរ៖ - ប្រាជ្ញ! វេទីបាន ប្រាប់អ្នកគ្រូថា សាថេ វាយកូនយក លុយ។ ប្រាប់អ្នកគ្រូឲ្យត្រង់មកមើល ថា មែន ឬមិនមែន? ឮសម្ដីអ្នកគ្រូ ខ្ញុំ ស្ទើរគាំងបេះដូង។ ដោយខ្លាច សាថេ ធ្វើបាប ខ្ញុំក៏ឆ្លើយកុហក៖ - មិនពិតទេ អ្នកគ្រូ!



ដោយខ្ញុំនិយាយកុហក អ្នកគ្រូហាក់ខឹងយ៉ាងខ្លាំង។ គាត់ក៏ដើរចេញទៅ។ ខ្ញុំលួចតាមមើលគាត់ ឃើញ គាត់ទៅរករឿង សាថេ។ - សាថេ ម៉េចបានជាឯងវាយប្រាជ្ញយកលុយ? - ខ្ញុំមិនបានធ្វើអីចឹងទេ! - បើឯងមិនសារភាព អ្នកគ្រូនឹងប្រាប់លោកនាយកឱ្យចាត់ការឯងមិនខាន។ (អ្នកគ្រូនិយាយគំរាម)



ខ្ញុំបានលួចមើលមុខអ្នកគ្រូ ឃើញមុខ
គាត់កាចណាស់។ ចំណែក សាថេ មុខ
ឡើងស្លេកអែ! ប៉ុន្តែគេនៅតែមិន ព្រម
សារភាព។ ដោយខឹងពេក អ្នកគ្រូក៏
ដើររ៉ុយសំដៅទៅទីចាត់ការ។ ពេល
ឃើញខ្ញុំ សាថេ ស្ទុះវឹងសំដៅមករក
វាយខ្ញុំ។ មុខគេដូចបិសាចអីចឹង។ ខ្ញុំ
ភ័យពេក ក៏ស្រែក និងរត់រកអ្នកគ្រូ
ជួយ។



សាថេ ក្តាប់ដៃយ៉ាងណែន។ គេខឹង
ណាស់ ប៉ុន្តែគេមិនហ៊ានវាយខ្ញុំមុខ
អ្នកគ្រូទេ។ អ្នកគ្រូ ក៏ហៅពួកយើងទៅ
ទីចាត់ការ។ - មើល៍ សាថេ! ម៉េចបាន
ចង់វាយប្រាជ្ញ? (នាយកសាលាសួរ សា
ថេ) - មកពីវាបង្ខូចខ្ញុំថា យកលុយវា។
- មើលប្រាជ្ញ! សាថេ មានយកលុយពី
ចៅទេ? (នាយកសាលាសួរខ្ញុំ)



លើកនេះ ខ្ញុំមិនអាចលាក់បានទៀត ទេ។ ខ្ញុំខ្លាច សាថេ វាយស្លាប់បើមិន និយាយការពិត។ - បាទលោកគ្រូ! សា ថេ យកលុយខ្ញុំរាល់ថ្ងៃ តាំងពីចុងខែធ្នូ ម្ល៉េះ។ - ឯងនិយាយកុហក! ខ្ញុំមិនដែល យកលុយឯងទេ កុំជឿវាលោកគ្រូ! - បើឯងមិនឆ្លើយការពិត។ លោកគ្រូ នឹងហៅអាណាព្យាបាលពួកឯងមក ជួប។ គ្រូប្រាប់ឲ្យហើយ បើ ប្រាជ្ញ របួស តែបន្តិច ឯងជាអ្នក ទទួលខុសត្រូវ។ ឮទេ?



លោកនាយកបានសរសេរសំបុត្រអញ្ជើញអាណាព្យាបាលសាថេ និងម្ដាយខ្ញុំ។ នៅព្រឹកថ្ងៃបន្ទាប់ អ្នកគ្រូបានជូនខ្ញុំទៅផ្ទះ។ គាត់ក៏ឆ្លៀតយកសំបុត្រជូនអាណាព្យាបាលខ្ញុំនិងសាថេផង។ ពីព្រោះផ្លូវទៅផ្ទះគាត់ កាត់មុខផ្ទះពួកយើង។ នៅតាមផ្លូវ គាត់ហាមខ្ញុំមិនឱ្យដើរលេងទេ ព្រោះខ្លាចសាថេស្ទាក់វាយ។



ព្រឹកស្អែកឡើង ម៉ែនាំខ្ញុំទៅទីចាត់ការ។ ពេលទៅដល់ ខ្ញុំឃើញអ្នកគ្រូ បីរ៉ាម៉ូ នាយកសាលា និងលោកគ្រូរបស់ សាថេ ។ ពួកគាត់អង្គុយចាំយើងនៅទីនោះស្រេចបាត់ទៅហើយ។ - អញ្ជើញចូលមកក្មួយស្រី! (នាយកសាលាហៅម៉ែខ្ញុំចូលក្នុងទីចាត់ការ) សូមរង់ចាំបន្តិច!



មិនយូរប៉ុន្មាន សាថេ និងប៉ារបស់គេ
ក៏មកដល់។ មុខ សាថេ ដូចជាស្លេក
ខុសពីធម្មតា។ ម៉ែខ្ញុំភ្ញាក់ព្រើត ពេល
បានឃើញ សាថេនិងប៉ារបស់គេមក
ដែរ។ ពេលជុំគ្នាហើយ លោកនាយកក៏
ចាប់ផ្ដើមរៀបរាប់អំពីរឿងរ៉ាវ ។



ពេលបានឮរឿងនេះ ម៉ែខ្ញុំនិយាយអ្វី
ក៏មិនចេញ។ ចំណែក ប៉ាសាថេខឹង
យ៉ាងខ្លាំង។ មិនគួរណា កូនគាត់ធ្វើរឿង
អ៊ីចឹងសោះ។ គាត់ក៏សួរកូនរកខុសត្រូវ
ដោយសម្ដីម៉ាត់ៗ៖ - មើលសាថេ!
ប្រាប់ឱ្យត្រង់មកមើល។ កូនបាន ធ្វើ
អ៊ីចឹងមែន ឬអត់ ?



ឮសំណួរភ្លាម សាថេចាប់ផ្ដើមស្លេក
បបូរមាត់ និយាយទាក់ៗ។ - មកពី
ប៉ាយកក្រដាសលំហាត់ខ្ញុំឲ្យទៅវា
ហើយសរសេរវាទៀត។ ទើបខ្ញុំចង់
ធ្វើបាបវា! - លំហាត់ថ្នាក់ទី៤ហ្នឹង កូន
លែងរៀនទៀតហើយ។ ប៉ាក៏ឱ្យមីងឯង
យកឱ្យកូនគាត់រៀន។ មីងឯងមិនសូវ
ចេះអក្សរទេ ទើបប៉ាជួយមើលថា កូន
គាត់ធ្វើត្រូវឬខុស។



- ខ្ញុំម៉េចដឹង! បើខ្ញុំឮតែប៉ា និងមីង សរសើរវាតែរហូត។ ថាវាធ្វើលំហាត់ត្រូវ។ - ឥឡូវកូនដឹងហើយ! ឈប់ខឹងឬនៅ ? - សុំទោសប៉ា! កូនខុសហើយ។ - មិនបាច់សុំទោសប៉ាទេ! សុំទោសប្រាជ្ញ និងលោកគ្រូ អ្នកគ្រូទៅ!



គេក៏បែរមកសុំទោសខ្ញុំ និងលោកគ្រូ
អ្នកគ្រូទាំងអស់នៅទីនោះ។ គ្រប់គ្នាក៏
ទទួលយក ការសុំទោសនេះ។ ព្រោះ
សាថេ ក៏ជាសិស្សឆ្នើមម្នាក់របស់
សាលាដែរ។ គេក៏មិនដែលធ្វើកំហុស
អ្វី លើកលែងតែកំហុសមួយនេះដែរ។
ម្ដាយខ្ញុំរកពាក្យថ្លែងមិនចេញ។ ម្ខាង
ជាកូនបង្កើត ម្ខាងជាក្មេងដែលគាត់
មើលថែតាំងពីតូច។



ពេលឃើញម្ដាយខ្ញុំយំ សាថេ
ក៏ពិបាកចិត្តដែរ។ មើលទៅ គេ
ស្រលាញ់ម្ដាយខ្ញុំណាស់។ គេនិយាយ
លួងលោមគាត់។ - មីងឈប់យំទៅ!
ខ្ញុំសន្យាថា មិនធ្វើបាបប្រាជ្ញទៀតទេ !
ហើយពេលមកសាលា ខ្ញុំតាមមើលថែ
គេជំនួសមីង។



ម៉ែខ្ញុំអរណាស់ពេលបានឮសម្ដីនេះ។ គាត់បាននិយាយអរគុណសាថេ និង ដាស់តឿនខ្ញុំ ៖ - ថ្ងៃក្រោយ ពេលមានរឿងអ្វីមួយ កូនត្រូវប្រាប់ចាស់ទុំ។ នៅសាលាកូនត្រូវប្រាប់ លោកគ្រូ អ្នកគ្រូ។ នៅផ្ទះ កូនត្រូវប្រាប់ម៉ែ និង លោកយាយ។ កូនមិនត្រូវលាក់ទេ នេះសំណាងហើយដែលមិនមានរឿងធំ។



ចំណែកខាងសាលាក៏មិនដេញដោល
វែងឆ្ងាយដែរ។ លោកនាយកគ្រាន់តែ
ដាស់តឿនសាថេ កុំឱ្យធ្វើដូច្នេះទៀត។
តែបើមានលើកក្រោយសាលានឹង
ចាត់ការតាមបទបញ្ជាផ្ទៃក្នុងរបស់
សាលាមិនខាន។ ក្រោយពីសម្រួល
គ្នាហើយ ប៉ាសាថេ និងម៉ែខ្ញុំក៏ត្រលប់
ទៅផ្ទះវិញទៅ។ ចំណែកពួកយើងក៏ត្រូវ
ចូលរៀនវិញដែរ។



ពេលចេញលេង សាថេបានឱ្យសំបុត្រមកខ្ញុំមួយច្បាប់។ ខ្ញុំក៏បើកមើល ៖ «ប្រាជ្ញឱ្យបង សុំទោស។ បងមិនគួរធ្វើបាបប្អូនសោះ។ ការពិត លុយដែលបងយកពីប្អូន បងបានរក្សា ទុកវា។ បងមិនបានចាយវាទេ។ នេះលុយរបស់ប្អូនទាំងអស់ដែលបងយកពីប្អូន។»។



ពេលឃើញលុយរបស់ខ្លួន ខ្ញុំសប្បាយចិត្តណាស់។ ខ្ញុំក៏រាប់គុណមើលឃើញគ្រប់ចំនួន! នេះរាប់ថាខ្ញុំសន្សំវាចុះ។ ចំណែកវេទី នាងក៏រីករាយមិនស្មើរដែរ។ ព្រោះពួកយើងខាន និយាយលេងជាមួយគ្នាយូរមកហើយ។ នៅមានរឿងល្អជាច្រើនទៀតដែលខ្ញុំត្រូវរៀបរាប់ប្រាប់អ្នកទាំងអស់គ្នា។ ប៉ុន្តែដោយសារពេលវេលាមិនអំណោយផល ខ្ញុំសូមគោរពលាតែប៉ុណ្ណោះសិនចុះ។

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
Prach and Sathae, author: Huot Sarith. illustrator: by Ouk Ratha. Published by The Asia Foundation, https://www.letsreadasia.org © The Asia Foundation. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Somey Chheang